ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០១១........សហវ.ស.រ.ហ.ហ

# សារាចរ
# ស្តីពី
# ការបិទបញ្ជីចំណូល-ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ ២០២៤

- យោងព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- យោងព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- យោងអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- យោងអនុក្រឹត្យលេខ ៣៥៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- យោងអនុក្រឹត្យលេខ ៣៥៥ អនក្រ.បក ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- យោងអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- យោងប្រកាសលេខ ៧៧២ សហវ.ប្រក ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងប្រកាសលេខ ៩២៦ សហវ.ប្រក.អថ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- យោងប្រកាសលេខ ៩២៧ សហវ.ប្រក.អថ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- យោងប្រកាសលេខ ៩២៩ សហវ.ប្រក.អថ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលគ្រឹះស្ថានសាធារណៈរដ្ឋបាលសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- យោងប្រកាសលេខ ៩៥៥ សហវ.ប្រក.អថ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបែងចែកឥណទានចំណាយថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាលសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣។

ដោយការិយបរិច្ឆេទនៃឆ្នាំថវិកាត្រូវចាប់ផ្តើមពីថ្ងៃទី ១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ (មាត្រា ១១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំអំពីនីតិវិធីបច្ចេកទេសដើម្បីធានាឱ្យការបិទបញ្ជីចំណូល-ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ ២០២៤ និងការងារត្រូវបំពេញនៅឆ្នាំ ២០២៥ ប្រព្រឹត្តទៅបានត្រឹមត្រូវនិងទាន់ពេលវេលា ដូចខាងក្រោម ÷

## I- **អំពីការបិទបញ្ជីចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ ២០២៤**

### **ក-អំពីចំណូលថវិកាថ្នាក់ជាតិ**

ប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ (ជំពូកទី ៤ ផ្នែកទី ២ និងមាត្រា ៣៦ នៃអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២៣)។ ដូចនេះ **ប្រាក់ចំណូលទាំងអស់ត្រូវប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ ជាកំហិត។ ដោយឡែក ចំណូលជាប្រាក់ដុល្លារអាមេរិករបស់មន្ទីរជំនាញតាមរាជធានី ខេត្ត ត្រូវបង់ចូលគណនីចំណូលជាប្រាក់ដុល្លារអាមេរិក របស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ ដើម្បីធ្វើការកត់ត្រាជាចំណូលថវិការបស់មន្ទីរសាមីឱ្យបានទាន់ពេលវេលា។**

### **ខ-អំពីចំណាយថវិកាថ្នាក់ជាតិ**

ការបិទបញ្ជីចំណាយ ត្រូវដំណើរការទៅតាមដំណាក់កាលចំណាយ និងពេលវេលាដូចតទៅ ÷

- **រាល់ការសន្យាចំណាយ**ក្រៅពីចំណាយបៀវត្ស ចំណាយក្រៅបន្ទុកបុគ្គលិកផ្សេងៗទៀត ដែលមានគោលការណ៍កំណត់ច្បាស់លាស់ និងចំណាយសម្រាប់គោលនយោបាយសង្គមកិច្ច **មិនអាចអនុវត្តក្រោយថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០២៤ បានទេ លើកលែងតែមុខចំណាយទាំងឡាយណាដែលមានការប្រញាប់ និងការចាំបាច់បំផុតមិនអាចខកខានបាននិងត្រូវតែមានឥណទានថវិកានៅសល់ទំនេរគ្រប់គ្រាន់** ហើយមានសេចក្តីបញ្ជាក់សមស្រប និងទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តែក៏**មិនឱ្យលើសពីថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០២៤** ដែរ។ ដោយឡែកចំណាយវិនិយោគដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) អាចអនុញ្ញាតឱ្យផ្តល់សន្យាចំណាយបានរហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ តាមភាពចាំបាច់ និងជាក់ស្តែង ផ្អែកតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- រាល់ការសន្យាចំណាយដែលបានអនុវត្តនីតិវិធីហិរញ្ញវត្ថុរួចហើយ ប៉ុន្តែពុំទាន់បានបោះផ្សាយអាណត្តិបើកប្រាក់ត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ ត្រូវប្រើប្រាស់ឥណទានថវិកានៃឆ្នាំបន្ទាប់។ រាល់ការសន្យាចំណាយមិនទាន់បានអនុវត្តនីតិវិធីហិរញ្ញវត្ថុ ត្រូវបានបដិសេធចោល ហើយត្រូវស្នើសុំធានាចំណាយជាថ្មីក្នុងករណីមានតម្រូវការចំណាយ ដោយប្រើប្រាស់ឥណទានថវិកានៃឆ្នាំ ២០២៥។ ចំពោះចំណាយអនុវត្តកិច្ចលទ្ធកម្មសាធារណៈដែលបាននិងកំពុងអនុវត្តនីតិវិធី ត្រូវបានអនុញ្ញាតឱ្យទូទាត់ដោយប្រើប្រាស់ឥណទានថវិកាឆ្នាំបន្ទាប់ដោយត្រូវមានភ្ជាប់សំណើសុំធានាចំណាយថ្មី ព្រមជាមួយអាណត្តិទូទាត់។
- ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវប្រមូលសក្ខីប័ត្រ និងលិខិតយុត្តិការចំណាយ ដែលបញ្ជាក់ពីសេវាដែលបានធ្វើរួច ដើម្បី**រៀបចំបោះផ្សាយអាណត្តិបើកប្រាក់ អាណត្តិនិយ័តកម្ម (រួមទាំងអាណត្តិទូទាត់ប្រាក់រង្វាន់) និង/ឬ ប្រតិបត្តិការចំណាយ (Voucher) ក្នុង FMIS រួចបញ្ជូនទៅឆ្លងទិដ្ឋាការពីអ្នកត្រួតពិនិត្យថវិកា យ៉ាងយូរត្រឹមវេលាម៉ោង ១៧ និង ៣០ នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤។**

• រតនាគារថ្នាក់កណ្ដាល និងរតនាគាររាជធានី ខេត្ត **ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់ អាណត្តិនិយ័តកម្ម (រួមទាំងអាណត្តិទូទាត់ប្រាក់រង្វាន់) និង/ឬ ប្រតិបត្តិការចំណាយ (Voucher) ក្នុង FMIS ឆ្នាំ ២០២៤ ត្រឹមវេលាម៉ោង ១៧ និង ៣០ នាទី នាថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០២៥។** ក្រោយកាលបរិច្ឆេទនេះ រតនាគារថ្នាក់កណ្ដាលត្រូវបញ្ជូនអាណត្តិបើកប្រាក់ទាំងនោះ ត្រឡប់ទៅអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបញ្ជូនបន្តទៅក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិវិញ ចំណែកឯរតនាគាររាជធានី ខេត្ត ត្រូវបញ្ជូនអាណត្តិបើកប្រាក់ទាំងនោះត្រឡប់ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីបញ្ជូនបន្តទៅមន្ទីរជំនាញរាជធានី ខេត្តវិញ ហើយអាណាប័កត្រូវបោះផ្សាយអាណត្តិបើកប្រាក់ថ្មីដោយប្រើប្រាស់ឥណទានថវិកាឆ្នាំ ២០២៤។

## គ-អំពីចំណាយតាមរជ្ជទេយ្យបុរេប្រទាន ចំណាយតាមនីតិវិធីបើកផ្ដល់សាច់ប្រាក់មុន និងបុរេប្រទាន

• **រជ្ជទេយ្យករបុរេប្រទាន** ត្រូវប្រមូលសក្ខីប័ត្រ និងលិខិតយុត្តិការចំណាយជូនអាណាប័ក ដើម្បីធ្វើការបោះផ្សាយ អាណត្តិនិយ័តកម្មទូទាត់ជម្រះបញ្ជីចំណាយតាមរជ្ជទេយ្យបុរេប្រទាន និងចំណាយតាមនីតិវិធីបើកផ្ដល់សាច់ប្រាក់មុន សម្រាប់ចំណាយបេសកកម្មនៅក្នុងប្រទេស ចំណាយរៀបចំវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗ ឱ្យបានទាន់ក្នុងឆ្នាំថវិកា ២០២៤។ រតនាគារថ្នាក់កណ្ដាល និងរតនាគាររាជធានី ខេត្ត **ត្រូវបញ្ឈប់ការទទួលអាណត្តិនិយ័តកម្មសម្រាប់ការទូទាត់បើកសាច់ប្រាក់លើចំណាយតាមរជ្ជទេយ្យបុរេប្រទាន និងចំណាយតាមនីតិវិធីបើកផ្ដល់សាច់ប្រាក់មុនចុងក្រោយបង្អស់នៅវេលាម៉ោង ១១ និង ៣០នាទី នាថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០២៤** នាពេលដំណាច់ឆ្នាំ រជ្ជទេយ្យករបុរេប្រទានត្រូវខិតខំរូតរះប្រមូលសក្ខីប័ត្រ និងលិខិតយុត្តិការចំណាយជូនអាណាប័ក ដើម្បីបោះផ្សាយអាណត្តិនិយ័តកម្ម **រួចបញ្ជូនទៅឆ្លងទិដ្ឋាការពីអ្នកត្រួតពិនិត្យថវិកា យ៉ាងយូរត្រឹមវេលាម៉ោង ១៧ និង ៣០ នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤** និងបញ្ជូនទៅរតនាគារថ្នាក់កណ្ដាល **និងរតនាគាររាជធានី ខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០២៥ ដើម្បីទូទាត់ជម្រះបញ្ជីចំណាយតាមរជ្ជទេយ្យបុរេប្រទាន និងចំណាយតាមនីតិវិធីបើកផ្ដល់សាច់ប្រាក់មុន ឱ្យបានទាន់ពេលវេលា។** ក្នុងករណីដែលមានប្រាក់រជ្ជទេយ្យបុរេប្រទាន និងប្រាក់ដែលអនុវត្តនីតិវិធីបើកផ្ដល់សាច់ប្រាក់មុននៅសល់ រជ្ជទេយ្យករបុរេប្រទានត្រូវយកសាច់ប្រាក់ដែលនៅសល់នោះ ទៅបង់ចូលគណនីចរន្តរបស់រតនាគារថ្នាក់កណ្ដាល ឬរតនាគាររាជធានី ខេត្ត នៅធនាគារ **យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ ដើម្បីចុះកិច្ចបញ្ជិកាជម្រះបញ្ជី។**

• **បុរេប្រទាន÷** រតនាគារថ្នាក់កណ្ដាល និងរតនាគាររាជធានី ខេត្ត **ត្រូវបញ្ឈប់ការទទួលលិខិតបុរេប្រទានសម្រាប់ការបើកផ្ដល់ប្រាក់បុរេប្រទានចុងក្រោយ នៅវេលាម៉ោង ១៧ និង ៣០ នាទី ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០២៤** ហើយការទូទាត់ប្រាក់បុរេប្រទាននេះ ត្រូវរូតរះប្រមូលឯកសារសុំទូទាត់ **យ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤។ ចំពោះប្រាក់បុរេប្រទានដែលនៅសល់ ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវយកមកបង់ចូលគណនីចរន្តរបស់**រតនាគារថ្នាក់កណ្ដាល ឬរតនាគាររាជធានី ខេត្តនៅធនាគារ **យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤។** ដោយឡែក ចំណាយវិនិយោគដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) អាចអនុញ្ញាតឱ្យផ្ដល់ប្រាក់បុរេប្រទានបានរហូតដល់ថ្ងៃទី **៣១ ខែ ធ្នូ ឆ្នាំ ២០២៤** តាមភាពចាំបាច់ និងជាក់ស្ដែង ផ្អែកតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ **ក្នុងករណីប្រាក់បុរេប្រទានឆ្នាំ ២០២៤ មិនបានធ្វើការទូទាត់ជម្រះបញ្ជីឱ្យអស់ក្នុងឆ្នាំថវិកា ២០២៤ នោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងកាត់ទុកឥណទានថវិកាសម្រាប់ទូទាត់បុរេប្រទាននោះក្នុងក្របខ័ណ្ឌកញ្ចប់ថវិកាឆ្នាំ ២០២៥ មុននឹងធ្វើការធានាចំណាយសម្រាប់ឆ្នាំ ២០២៥។**

• យោងតាមសារាចរណែនាំលេខ ០០៨ សហវ.ហក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីបែបបទនៃការទូទាត់ជូនក្រុមហ៊ុន Royal Cambodian Limousine Service Co., Ltd លើថ្លៃសេវារថយន្តប្រណិតក្នុងការដឹកជញ្ជូន

គណៈប្រតិភូ និងភ្ញៀវបរទេសនានា ដែលមកបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា ការទូទាត់ថ្លៃសេវាប្រើប្រាស់រថយន្តប្រណិតជូនក្រុមហ៊ុន Royal Cambodian Limousine Service Co.,Ltd *ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់កណ្តាលត្រូវតែរះបោះផ្សាយអាណត្តិនិយ័តកម្ម រួចបញ្ជូនទៅឆ្លងទិដ្ឋាការពីអ្នកត្រួតពិនិត្យថវិកាយ៉ាងយូរត្រឹមវេលាម៉ោង ១៧ និង ៣០ នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ និងត្រូវបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិឱ្យបានមុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០២៥។* នៅមុនដំណាច់ឆ្នាំអនុវត្តថវិកា អគ្គនាយកដ្ឋានថវិកាត្រូវសហការជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ និងក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ដើម្បីធ្វើការបូកសរុបចំណាយជាក់ស្តែងសម្រាប់សេវាដឹកជញ្ជូនថ្នាក់ជាតិ រួចធ្វើការប្រៀបធៀបជាមួយកម្រៃអប្បបរមាដែលត្រូវបង់ជូនក្រុមហ៊ុនដូចមានចែងក្នុងកិច្ចព្រមព្រៀង។ ក្នុងករណីដែលចំនួនទឹកប្រាក់ចំណាយសរុបទាំងអស់ ដែលបានបោះផ្សាយអាណត្តិនិយ័តកម្ម តិចជាងចំនួនប្រាក់ដែលបានផ្តល់មុនជូនក្រុមហ៊ុន Royal Cambodian Limousine Service Co.,Ltd ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គលេខាធិការដ្ឋាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ) ត្រូវធ្វើការបោះផ្សាយអាណត្តិបើកប្រាក់ដើម្បីកត់ត្រាចំណាយបង្គ្រប់។

- ក្នុងករណីមានការខ្វះឥណទានថវិកាសម្រាប់ធ្វើការទូទាត់បុរេប្រទាន អាណាប័កត្រូវមានវិធានការជាបន្ទាន់តាមការជាក់ស្តែង ជាអាទិ៍៖

 - លើកសំណើសុំធ្វើនិយ័តកម្មថវិកាផ្ទៃក្នុងដែលសល់ទំនេរ មកបំពេញឱ្យខ្ទង់ថវិកាដែលត្រូវបោះផ្សាយអាណត្តិនិយ័តកម្ម ក្នុងនោះគិតរួមទាំងប្រាក់បុរេប្រទានឆ្នាំមុនៗផងដែរ។

 - កាត់បន្ថយ ឬផ្អាកជាបណ្តោះអាសន្ននូវទឹកប្រាក់បានធានាចំណាយមួយចំនួន ដែលមិនសូវចាំបាច់សំដៅធានាឱ្យមានឥណទានគ្រប់គ្រាន់ សម្រាប់ធ្វើការជម្រះបញ្ជីបុរេប្រទានឱ្យបានជ្រះស្រឡះ។

### ឃ-អំពីចលនាឥណទាន

**ការធ្វើនិយ័តកម្មឥណទានថវិកា** សម្រាប់ការទូទាត់ចំណាយចាំបាច់ ឬទូទាត់រជ្ជទេយ្យបុរេប្រទាន ឬទូទាត់បុរេប្រទាន**ត្រូវបញ្ឈប់នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០២៤**។ ដូច្នេះ ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ត្រូវបញ្ជូនសំណុំលិខិតស្នើសុំធ្វើនិយ័តកម្មឥណទានថវិកាមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២៤**។ ដោយឡែក ក្រសួង ស្ថាប័ន ដែលកំពុងអនុវត្តនីតិវិធីចលនាឥណទានថវិកាថ្មីតាម FMIS **ត្រូវបញ្ឈប់ចលនាឥណទានថវិកាតាម FMIS នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០២៤**។

### ង-អំពីកិច្ចប្រតិបត្តិការនិយ័តកម្ម

ប្រតិបត្តិការនិយ័តកម្ម នៃរតនាគារសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ត្រូវបន្តរហូតដល់ថ្ងៃទី ២៨ ខែ កុម្ភៈ **ឆ្នាំ ២០២៥**។ ប្រតិបត្តិការនិយ័តកម្មនេះ ត្រូវបានពិនិត្យកត់ត្រាជាលេខនាបន្ថែមនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ ដែលទាក់ទងទៅនឹង៖

- ការកត់ត្រាជាស្ថាពរនៃចំណូល ឬចំណាយដែលបានពិនិត្យកត់ត្រាជាលេខនាថ្ងៃទី **៣១ ខែ ធ្នូ ឆ្នាំ ២០២៤** ជាអាទិ៍ដែលបានកត់ត្រាចូលគណនីបណ្តោះអាសន្ន
- អាណត្តិនិយ័តកម្មដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករចំណូល មុនថ្ងៃទី **៣១ ខែ ធ្នូ ឆ្នាំ ២០២៤**
- ការកែតម្រូវលេខនាខុស
- កិច្ចប្រតិបត្តិការដែលប្រមូលពីគណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត។

## ច-អំពីកិច្ចប្រតិបត្តិការថវិកាឆ្នាំ ២០២៥

១-អនុញ្ញាតឱ្យក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ រៀបចំគម្រោង និងស្នើសុំធានាចំណាយថវិកាសម្រាប់ឆ្នាំ ២០២៥ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលា នៅក្នុងត្រីមាសទី ៤ នៃឆ្នាំ ២០២៤។ ថវិកាស្នើសុំធានាចំណាយត្រូវឈរលើមូលដ្ឋាន ៥០% នៃមុខចំណាយនីមួយៗ នៃកញ្ចប់ថវិកាឆ្នាំ ២០២៤ លើកលែងតែក្រសួង ស្ថាប័នមួយចំនួន ដែលអនុញ្ញាតឱ្យស្នើសុំធានាចំណាយ ១០០% នៃកញ្ចប់ថវិកាឆ្នាំ ២០២៤ លើមុខចំណាយខ្លះប៉ុណ្ណោះ ដោយក្នុងនោះមាន៖ (១)-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ សម្រាប់ទិញអង្ករ និងឯកសណ្ឋាន, (២)-ក្រសួងសុខាភិបាល សម្រាប់ការទិញឱសថនិងបរិក្ខារពេទ្យ, និង (៣)-ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការបោះពុម្ពសៀវភៅគោល និងកម្មសិទ្ធិបញ្ញា។ ដោយឡែក សម្រាប់គម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់និងប្រព័ន្ធធារាសាស្ត្រ និងចំណាយសម្រាប់ការសិក្សាគម្រោងវិនិយោគផ្ទាល់, ក្រសួង ស្ថាប័ន ក៏អាចចាប់ផ្តើមស្នើសុំធានាចំណាយ នៅក្នុងអំឡុងត្រីមាសទី៤ នៃឆ្នាំ ២០២៤ ផងដែរ ផ្អែកតាមផែនការប្រចាំឆ្នាំដែលបានទទួលការសម្រេចរួចហើយ។

២-គម្រោងស្នើសុំធានាចំណាយត្រូវធ្វើឡើងចំពោះតែមុខចំណាយសម្រាប់ទំនិញ បរិក្ខារ សេវា ឬការសាងសង់ ការជួសជុល ថែទាំទាំងឡាយណា ដែលមានរយៈពេលវែងក្នុងការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។

៣-ពេលទទួលបានលិខិតធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវដំណើរការរៀបចំកិច្ចលទ្ធកម្មសាធារណៈឱ្យបានរួសរាន់ ដើម្បីឱ្យសាមីក្រសួង ស្ថាប័នទទួលបានទំនិញ សេវា ឬការជួសជុលថែទាំមកប្រើប្រាស់តាមការគ្រោងទុក។

៤-ក្រសួង ស្ថាប័ន ត្រូវរូតរះស្នើសុំធានាចំណាយ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈស្របតាមផែនការលទ្ធកម្មឱ្យបានទាន់ពេលវេលា ជៀសវាងការទូទាត់ត្រូវធ្វើឡើងជាគំហុកនៅពេលណាមួយ ជាពិសេសនៅចុងឆ្នាំ។

៥-ចំពោះការបង់ប្រាក់បុរេប្រទាន រដ្ឋទេយ្យបុរេប្រទានសល់ និងសំណៃសចំណាយ ត្រូវអនុវត្តតាមសារាចរណែនាំលេខ ០០៩ សហវ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ស្តីពីការបង់ប្រាក់បុរេប្រទាន រដ្ឋទេយ្យបុរេប្រទាន និងសំណៃសចំណាយ។

៦-រាល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ ២០២៥ ត្រូវផ្អែកលើកម្មវិធីចំណូល ចំណាយប្រចាំខែ និងត្រីមាសដែលក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងមន្ទីរជំនាញរាជធានី ខេត្តត្រូវរៀបចំ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា-នាយកដ្ឋានថវិកានីយកម្ម) ក្នុងរយៈពេល ២ សប្តាហ៍ក្រោយពីច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ត្រូវបានអនុម័ត។

៧-ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវរៀបចំតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន និងតារាងគម្រោងចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុនសម្រាប់ចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេស ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំផ្សេងៗសម្រាប់ឆ្នាំ ២០២៥ រួចបញ្ជូនមកអ្នកត្រួតពិនិត្យថវិកា និងគណនេយ្យករសាធារណៈឱ្យបានមុនដំណាច់ខែ វិច្ឆិកា (មុនឆ្នាំអនុវត្ត) ដើម្បីអាចបញ្ចូលទិន្នន័យឥណទានថវិការដ្ឋទេយ្យបុរេប្រទាន និងគម្រោងចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុនសម្រាប់ឆ្នាំ ២០២៥ ទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ឱ្យបានរួចរាល់មុនដំណាច់ខែ ធ្នូ ឆ្នាំ ២០២៤ ដោយផ្អែកតាមលទ្ធផលនៃការពិភាក្សាការពារគម្រោងថវិកា និងបទប្បញ្ញត្តិនៃប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ប្រកាសលេខ ០៩៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងប្រកាសលេខ ១០២ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ សម្រាប់រដ្ឋបាលថ្នាក់ជាតិ។

## II- អំពីការបិទបញ្ជីចំណូល-ចំណាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលឆ្នាំ ២០២៤

### ក-អំពីចំណូលថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

ប្រាក់ចំណូលទាំងអស់របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបង់ចូលគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល នៅរតនាគារពាក់ព័ន្ធ និង/ឬ នៅធនាគារជាតិនៃកម្ពុជា និង/ឬ នៅធនាគារពាណិជ្ជដៃគូ **យ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤។** ក្នុងករណីគ្រឹះស្ថានសាធារណៈរដ្ឋបាល មានចំណូលហួតដល់ល្ងាចថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ ហើយពុំអាចបង់ចូលគណនីនៅធនាគារបាន សាច់ប្រាក់ចំណូលតាមរយៈរដ្ឋទេយ្យករចំណូលនោះត្រូវបង្វែរទៅបេឡារបស់គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីកត់ត្រាជាចំណូលថវិកាឆ្នាំ២០២៤។

### ខ-អំពីចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

ការបិទបញ្ជីចំណាយ ត្រូវដំណើរការទៅតាមដំណាក់កាលចំណាយ និងពេលវេលាដូចតទៅ៖

- **រាល់ចំណាយ**ក្រៅពីចំណាយបៀវត្ស ចំណាយក្រៅបន្ទុកបុគ្គលិកផ្សេងៗទៀត ដែលមានគោលការណ៍កំណត់ច្បាស់លាស់ និងចំណាយសម្រាប់គោលនយោបាយសង្គមកិច្ចដែលមានរបប **មិនអាចអនុវត្តក្រោយថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២៤ បានទេ។**
- រាល់ចំណាយមិនទាន់បានអនុវត្តនីតិវិធីហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ ត្រូវបានបដិសេធចោល ហើយត្រូវស្នើសុំធានាចំណាយជាថ្មី ក្នុងករណីមានតម្រូវការចំណាយ ដោយប្រើប្រាស់ឥណទានថវិកានៃឆ្នាំ ២០២៥ លើកលែងតែចំណាយឆ្លងនីតិវិធីលទ្ធកម្មដែលបាន និងកំពុងអនុវត្ត ត្រូវបានអនុញ្ញាតឱ្យទូទាត់ដោយប្រើប្រាស់ឥណទានថវិកាឆ្នាំបន្ទាប់ដោយត្រូវមានភ្ជាប់សំណើសុំធានាចំណាយថ្មី ព្រមជាមួយអាណត្តិទូទាត់។
- គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវប្រមូលសក្ខីប័ត្រ និងលិខិតយុត្តិការចំណាយ ដែលបញ្ជាក់ពីសេវាបានបំពេញ ដើម្បីរៀបចំបោះផ្សាយអាណត្តិបើកប្រាក់ និងដាក់ឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ឱ្យបានទាន់ពេលវេលាក្នុងឆ្នាំ ២០២៤។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវឈប់ទទួលអាណត្តិបើកប្រាក់ឆ្នាំ ២០២៤ យ៉ាងយូរបំផុតត្រឹមវេលាម៉ោង ១៧ និង ៣០ នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤។**

### គ-អំពីចំណាយតាមរដ្ឋទេយ្យបុរេប្រទាន និងបុរេប្រទានរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

- រដ្ឋទេយ្យករបុរេប្រទាន ត្រូវខិតខំរួតរះប្រមូលសក្ខីប័ត្រ និងលិខិតយុត្តិការចំណាយជូនអាណាប័ក តាមរយៈមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ជម្រះបញ្ជីចំណាយតាមរដ្ឋទេយ្យបុរេប្រទាន និងដាក់ឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងបញ្ជូនទៅគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល **យ៉ាងយូរត្រឹមវេលាម៉ោង ១៧ និង ៣០ នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤។** ក្នុងករណីដែលមានប្រាក់រដ្ឋទេយ្យបុរេប្រទាននៅសល់ រដ្ឋទេយ្យករបុរេប្រទានត្រូវយកសាច់ប្រាក់ដែលនៅសល់នោះ ទៅបង់ចូលគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈ រដ្ឋបាលនៅរតនាគារពាក់ព័ន្ធ និង/ឬ ធនាគារជាតិនៃកម្ពុជា និង/ឬ ធនាគារពាណិជ្ជដៃគូ **យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤** ដើម្បីចុះកិច្ចបញ្ជិកាជម្រះបញ្ជី។ ក្នុងករណីដែលមានតម្រូវការចាំបាច់ គ្រឹះស្ថានសាធារណៈរដ្ឋបាលអាចរក្សាទុកមួយផ្នែកនៃសាច់ប្រាក់រដ្ឋទេយ្យបុរេប្រទានដែលនៅសល់នាពេលដំណាច់ឆ្នាំ សម្រាប់ការប្រើប្រាស់ជារដ្ឋទេយ្យបុរេប្រទានក្នុងជុំបង្វិលទី ១ នៃរដ្ឋទេយ្យបុរេប្រទានសម្រាប់ថវិកាឆ្នាំ ២០២៥។ ទឹកប្រាក់នេះ នឹងជាកម្មវត្ថុនៃការដកចេញ ពីកញ្ចប់សាច់ប្រាក់រដ្ឋទេយ្យបុរេប្រទានជុំទី ១ នៃឆ្នាំថវិកា ២០២៥។
- គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលបានប្រើប្រាស់ប្រាក់បុរេប្រទាន ត្រូវរួតរះប្រមូលឯកសារទូទាត់ប្រាក់បុរេប្រទាន **ឱ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤។** ចំពោះប្រាក់បុរេប្រទានដែលនៅសល់ គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវយកមកបង់ចូលគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារពាក់ព័ន្ធ និង/ឬ ធនាគារជាតិនៃកម្ពុជា និង/ឬ ធនាគារពាណិជ្ជដៃគូ **យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤។**

**ឃ-អំពីការទូទាត់ប្រាក់ខ្ចាន់**

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវវូតរះប្រមូលលិខិតយុត្តិការចំណាយក្នុងការបើកផ្តល់ប្រាក់រង្វាន់ ដើម្បីរៀបចំបោះផ្សាយអាណត្តិនិយ័តកម្ម និងដាក់ឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល **យ៉ាងយូរត្រឹមវេលាម៉ោង ១៧ និង ៣០ នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤។**

**ង-អំពីការទូទាត់សេវាធនាគារ និងពន្ធលើកម្រៃការប្រាក់**

គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវវូតរះប្រមូលលិខិតយុត្តិការចំណាយប្រាក់ក្នុងការទូទាត់សេវាធនាគារ និងពន្ធលើកម្រៃការប្រាក់ ដើម្បីរៀបចំបោះផ្សាយអាណត្តិនិយ័តកម្ម និងដាក់ឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល **យ៉ាងយូរត្រឹមវេលាម៉ោង ១៧ និង ៣០ នាទី ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤។**

**ច-អំពីចលនាឥណទាន**

**ការធ្វើនិយ័តកម្មឥណទានថវិកាផ្ទៃក្នុងជំពូកតែមួយ ត្រូវបញ្ឈប់ត្រឹមថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០២៤។** ក្នុងករណីនិយ័តកម្មឆ្លងជំពូក គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបញ្ជូនសំណុំលិខិតស្នើសុំនិយ័តកម្មឥណទានមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២៤។**

**ឆ-អំពីកិច្ចប្រតិបត្តិការថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលឆ្នាំ ២០២៥**

១-ក្នុងត្រីមាសទី ១ គ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ អាចរៀបចំសំណើសុំផ្តល់បុរេប្រទានឧបត្ថម្ភធនស្មើនឹង ១ ភាគ ៤ នៃថវិកាឧបត្ថម្ភធនប្រចាំឆ្នាំរបស់ខ្លួន មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ)។

២-ចំពោះការបង់ប្រាក់បុរេប្រទាននៅសល់ រដ្ឋទេយ្យបុរេប្រទាននៅសល់ និងសំណល់សចំណាយ ត្រូវអនុវត្តតាមសារាចរណែនាំលេខ ០០៩ សហវ ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៥ ស្តីពីការបង់ប្រាក់បុរេប្រទាន រដ្ឋទេយ្យបុរេប្រទាន និងសំណល់សចំណាយ **ត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៥។**

៣-អនុញ្ញាតឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាល រៀបចំគម្រោងនិងស្នើសុំបង្កើតរដ្ឋទេយ្យបុរេប្រទានសម្រាប់ឆ្នាំ ២០២៥ ចាប់ពីចុងខែ តុលា ឆ្នាំ ២០២៤ ដើម្បីអាចបង្កើតរដ្ឋទេយ្យបុរេប្រទានបានទាន់ពេលវេលា នាដើមឆ្នាំថវិកា ២០២៥។ សេចក្តីព្រាងតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានដែលស្នើសុំបង្កើតត្រូវផ្អែកលើមូលដ្ឋានគម្រោងថវិកាឆ្នាំ ២០២៥។ ក្នុងករណីការបង្កើតតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានមានការយឺតយ៉ាវ គ្រឹះស្ថានសាធារណៈរដ្ឋបាលអាចស្នើសុំដកប្រាក់ពីរតនាគារឬពីធនាគារតាមជំពូកចាស់ ឬតាមសេចក្តីព្រាងនៃតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានដែលមានហត្ថលេខារបស់រដ្ឋទេយ្យករបុរេប្រទាននិងនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ជ-ការណែនាំលម្អិតស្តីពីកិច្ចបញ្ជិកាគណនេយ្យឆ្នាំ ២០២៤ និងឆ្នាំ ២០២៥** មានចែងនៅក្នុងសារាចរស្តីពីការបិទបញ្ជីគណនេយ្យឆ្នាំ ២០២៤ និងទិសដៅការងារឆ្នាំ ២០២៥ របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

## III- ការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ ២០២៤

### ក. ការបូកសរុបការអនុវត្តថវិកាថ្នាក់ជាតិឆ្នាំ ២០២៤ ត្រូវដំណើរការ ដូចតទៅ៖

- ចាប់ពីថ្ងៃទី **១ ខែ មករា ឆ្នាំ ២០២៥** អគ្គនាយកដ្ឋានថវិកាត្រូវបូកសរុបចលនាឥណទានថវិកានិងឥណទានវិចារណកម្មចំណាយ តាមចំណាត់ថ្នាក់សេដ្ឋកិច្ចឆ្នាំ ២០២៤ តាមក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ដើម្បីរៀបចំស្ថានភាពឥណទានថ្មី រួចបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ (នាយកដ្ឋានចំណាយថវិកា) **យ៉ាងយូរត្រឹមថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០២៥។**

• ចាប់ពី**ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០២៥** អគ្គនាយកដ្ឋានរតនាគារជាតិត្រូវដំណើរការបូកសរុបកិច្ចប្រតិបត្តិការរតនាគារទូទាំងប្រទេសអំពីការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ ២០២៤ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា-នាយកដ្ឋានថវិកានីយកម្ម) **យ៉ាងយូរត្រឹមថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២៥។**

• ចាប់ពី**ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០២៥** គ្រប់មន្ទីរជំនាញរាជធានី ខេត្ត ត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខអនុវត្តចំណូល ចំណាយថវិការបស់អង្គភាពជាមួយរតនាគាររាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយត្រូវរៀបចំរបាយការណ៍បូកសរុបអនុវត្តចំណូល ចំណាយថវិកា រួចផ្ញើមករតនាគាររាជធានី ខេត្ត មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាមី **ឱ្យបានមុនថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០២៥។**

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានភារកិច្ចបូកសរុបការអនុវត្តចំណូល ចំណាយរបស់មន្ទីរជំនាញរាជធានី ខេត្ត ដែលបានផ្ទៀងផ្ទាត់ រួចផ្ញើមកអគ្គនាយកដ្ឋានថវិកា (នាយកដ្ឋានថវិកានីយកម្ម) **ឱ្យបានមុនថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២៥ ជាកំហិត។**

រតនាគាររាជធានី ខេត្ត មានភារកិច្ចបូកសរុបការអនុវត្តចំណូល ចំណាយរបស់មន្ទីរជំនាញរាជធានី ខេត្ត ដែលបានផ្ទៀងផ្ទាត់ រួចផ្ញើមកអគ្គនាយកដ្ឋានរតនាគារជាតិ **ឱ្យបានមុនថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២៥ ជាកំហិត។**

ចំពោះក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវបូកសរុបផ្ទៀងផ្ទាត់តួលេខចំណូល ចំណាយថវិកាជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (ចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស)។ **ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិត្រូវរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកា សម្រាប់របាយការណ៍ចំណាយថវិកាព្រមទាំងបញ្ចូលតួលេខចំណូល ចំណាយថវិការបស់មន្ទីរជំនាញរាជធានី ខេត្ត ដែលស្ថិតនៅក្រោមឱវាទ** រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ-នាយកដ្ឋានចំណូលថវិកា-នាយកដ្ឋានចំណាយថវិកា និងអគ្គនាយកដ្ឋានថវិកា-នាយកដ្ឋានថវិកានីយកម្ម) **ឱ្យបានមុនថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២៥ ជាកំហិត។**

ចំពោះចំណាយវិនិយោគផ្ទាល់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ សុខាភិបាល និងផ្នែកអប់រំ យុវជន និងកីឡា និងចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស ក្រសួង ស្ថាប័នត្រូវផ្ទៀងផ្ទាត់តួលេខអនុវត្តជាមួយអង្គភាពគ្រប់គ្រងគម្រោងរបស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនីមួយៗ ហើយរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយវិនិយោគប្រចាំឆ្នាំ ២០២៤ រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងនោះមាន៖ អគ្គនាយកដ្ឋានគោលនយោបាយ អគ្គនាយកដ្ឋានរតនាគារជាតិ (នាយកដ្ឋានចំណាយថវិកា) អគ្គនាយកដ្ឋានថវិកា (នាយកដ្ឋានថវិកានីយកម្ម-នាយកដ្ឋានវិនិយោគ) និងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល **ឱ្យបានមុនថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២៥ ជាកំហិត។**

ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ មន្ទីរជំនាញរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវរៀបចំរបាយការណ៍បូកសរុបការអនុវត្តថវិការបស់ខ្លួនទៅតាមតារាងគំរូដែលមានភ្ជាប់មកជាមួយនេះ រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានតាមកាលកំណត់ខាងលើ ដើម្បីឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ) អាចបូកសរុប និងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច និងស្ថាប័ននីតិប្បញ្ញត្តិពិនិត្យនិងអនុម័ត ឱ្យបានទាន់ពេលវេលា។ ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិត្រូវរៀបចំរបាយការណ៍អំពីស្ថានភាពសាច់ប្រាក់បុរេប្រទានដែលនៅសល់គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ ទៅតាមតារាងគំរូដែលមានភ្ជាប់មកជាមួយនេះ (ឧបសម្ព័ន្ធ ១២) រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ) **ឱ្យបានមុនថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២៥ ជាកំហិត** ដើម្បីបូកសរុបនិងរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ឱ្យបានទាន់ពេលវេលា។ ក្នុងករណីដែលប្រាក់បុរេប្រទាននៅសល់ជាប្រាក់ដុល្លារអាម៉េរិក ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិត្រូវប្រើប្រាស់អត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ខាងលើ។

ក្នុងករណីក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ មន្ទីរជំនាញរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្ញើរបាយការណ៍បូកសរុបទូទាត់មិនទាន់ពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងយកតួលេខរបាយ-ការណ៍បូកសរុបរបស់អគ្គនាយកដ្ឋានរតនាគារជាតិធ្វើជាតួលេខផ្លូវការ។

**ខ. ការបូកសរុបការអនុវត្តថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាលឆ្នាំ ២០២៤ ត្រូវដំណើរការដូចតទៅ៖**

**ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២៥** គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវដំណើរការបូកសរុបកិច្ចប្រតិបត្តិការគណនេយ្យនិងហិរញ្ញវត្ថុ សម្រាប់ការអនុវត្តថវិកាឆ្នាំ ២០២៤ និងធ្វើការផ្ទៀងផ្ទាត់តួលេខចំណូល និងចំណាយថវិកា ជាមួយនឹងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវរៀបចំរបាយការណ៍អនុវត្តចំណូលនិងចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រួចបញ្ជូនមកអគ្គនាយកដ្ឋានថវិកា និងចម្លងជូនអគ្គនាយកដ្ឋានរតនាគារជាតិ **យ៉ាងយូរត្រឹមថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២៥**។ រីឯ គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រួចបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការបូកសរុប **យ៉ាងយូរត្រឹមថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២៥**។

គ្រប់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ អគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានរតនាគារជាតិ មន្ទីរជំនាញរាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធទាំងឡាយ ត្រូវអនុវត្តសារាចរនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល</u>** ÷

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អាជ្ញាធរសវនកម្មជាតិ

"ដើម្បីជូនជ្រាបជាព័ត៌មាន"

-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល

-អគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-រតនាគាររាជធានី ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត

"ដើម្បីអនុវត្ត"

-ឯកសារ -កាលប្បវត្តិ

ក្រសួង.......................

**ឧបសម្ព័ន្ធ ១**

## របាយការណ៍ចំណូលថវិកាថ្នាក់ជាតិ
## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

ឯកតា៖រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | សមាមាត្រ (%) | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣=២/១ | |
| | | | សរុបរួម (I+II) | | | | |
| | | | I- ផ្នែករដ្ឋបាលកណ្តាល | | | | |
| | | | II- ផ្នែកមន្ទីរជំនាញរាជធានី ខេត្ត | | | | |
| | | | សរុបរួម | | | | |

| ហត្ថលេខានិងត្រា<br>ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ | ហត្ថលេខានិងត្រា<br>រដ្ឋមន្ត្រី | ហត្ថលេខា<br>ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ | ហត្ថលេខា<br>អ្នកធ្វើតារាង |
|---|---|---|---|

ក្រសួង.......................

<table><tr><td>ឧបសម្ព័ន្ធ ២</td></tr></table>

# របាយការណ៍ចំណាយថវិកាថ្នាក់ជាតិ
# សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

ឯកតា៖រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | ចលនាឥណទាន | | | | | ឥណទានវិចារណកម្ម | ស្ថានភាពឥណទានថ្មី | អនុវត្តជាក់ស្តែង | ឥណទាននៅសល់ | សមាមាត្រ (%) | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | កើន | | | | ថយ | | | | | | |
| | | | | | ចលនាផ្ទៃក្នុង | ឥណទានមិនបានគ្រោងទុក | បំពេញបន្ថែម | សរុប | | | | | | | |
| | | | | ១ | ២ | ៣ | ៤ | ៥=២+៣+៤ | ៦ | ៧ | ៨=១+៥-៦-៧ | ៩ | ១០ = ៨-៩ | ១១ = ៩/៨ | ១២ |
| សរុបរួម (I+II) | | | | | | | | | | | | | | | |
| ១-សរុបចំណាយចរន្ត | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| ២-សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| I. ផ្នែករដ្ឋបាលកណ្តាល | | | | | | | | | | | | | | | |
| ១-សរុបចំណាយចរន្ត | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| ២-សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| II. ផ្នែកមន្ទីរជំនាញរាជធានី ខេត្ត | | | | | | | | | | | | | | | |
| ១-សរុបចំណាយចរន្ត | | | | | | | | | | | | | | | |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | ចលនាឥណទាន | | | | | ឥណទានវិចារណកម្ម | ស្ថានភាពឥណទានថ្មី | អនុវត្តជាក់ស្តែង | ឥណទាននៅសល់ | សមាមាត្រ (%) | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | កើន | | | | ថយ | | | | | | |
| | | | | | ចលនាផ្ទៃក្នុង | ឥណទានមិនបានគ្រោងទុក | បំពេញបន្ថែម | សរុប | | | | | | | |
| | | | | ១ | ២ | ៣ | ៤ | ៥=២+៣+៤ | ៦ | ៧ | ៨=១+៥-៦-៧ | ៩ | ១០ = ៨-៩ | ១១ = ៩/៨ | ១២ |
| | | | | | | | | | | | | | | | |
| ២-សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |

ហត្ថលេខានិងត្រា
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ

ហត្ថលេខានិងត្រា
រដ្ឋមន្ត្រី

ហត្ថលេខា
ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ

ហត្ថលេខា
អ្នកធ្វើតារាង

ក្រសួង.......................

ឧបសម្ព័ន្ធ ៣

## របាយការណ៍ចំណាយវិនិយោគផ្ទាល់ផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ សុខាភិបាល ផ្នែកអប់រំ និងផ្នែកសន្តិសុខ-សណ្តាប់ធ្នាប់សាធារណៈ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

ឯកតា ៖រៀល

| បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | ស្ថានភាព ឥណទានថ្មី | អនុវត្តជាក់ស្តែង |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

ហត្ថលេខានិងត្រា
រដ្ឋមន្ត្រី

ហត្ថលេខា
ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ

ហត្ថលេខា
អ្នកធ្វើតារាង

ក្រសួង....................
Ministry of ......................

ឧបសម្ព័ន្ធ ៤

# របាយការណ៍ចំណាយសង្ខេបសរុបរួម សម្រាប់គម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ក្នុងក្រសួង ស្ថាប័ន

SUMMARY CONSOLIDATION EXPENDITURE REPORT FOR DP FUNDED PROJECTS WITHIN LINE MINISTRY

## ពីថ្ងៃទី ១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤

From 1st January to 31th December 2024

ឯកតា៖ដុល្លារ

| លេខ No. | ឈ្មោះគម្រោង / PROJECT'S NAME | ដៃគូអភិវឌ្ឍន៍ DPs | ចំណាយជាក់ស្តែងប្រចាំឆ្នាំ/Current Year Expenses | | | |
|---|---|---|---|---|---|---|
| | | | ថវិកាបដិភាគ Counterpart Fund | ឥណទាន LOAN | ហិរញ្ញប្បទានឥតសំណង GRANT | សរុប TOTAL |
| | | | 1 | 2 | 3 | 4=1+2+3 |
| 1 | (ឈ្មោះគម្រោង /Project's Name) | | - | - | - | - |
| 2 | (ឈ្មោះគម្រោង /Project's Name) | | - | - | - | - |
| 3 | (ឈ្មោះគម្រោង /Project's Name) | | - | - | - | - |
| 4 | (ឈ្មោះគម្រោង /Project's Name) | | - | - | - | - |
| 5 | (ឈ្មោះគម្រោង /Project's Name) | | - | - | - | - |
| 6 | (ឈ្មោះគម្រោង /Project's Name) | | - | - | - | - |
| 7 | (ឈ្មោះគម្រោង /Project's Name) | | - | - | - | - |
| **សរុបរួម**/GRAND TOTAL | | | - | - | - | - |

ហត្ថលេខានិងត្រា
រដ្ឋមន្ត្រី

ហត្ថលេខា
ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ

ហត្ថលេខា
អ្នកធ្វើតារាង

ក្រសួង.....................
Ministry of .......................
ឈ្មោះគម្រោង/ Project's Name.........
លេខគម្រោង/Project No.:xxxxx

**ឧបសម្ព័ន្ធ ៥**

## របាយការណ៍ចំណាយថវិកាតាមជំពូក គណនី អនុគណនីប្រចាំឆ្នាំរបស់គម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍

STATEMENT OF EXPENDITURE BY CHAPTER ACCOUNTS AND SUB-ACCOUNTS FOR DP FUNDED PROJECTS

### ពីថ្ងៃទី ១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤

From 1st January to 31th December 2024

ឯកតា៖ដុល្លារ

| ប្លង់គណនេយ្យ (CoA) | | | បរិយាយ Description | កំណត់សំគាល់ Notes | ផែនការថវិកាប្រចាំឆ្នាំ Annual Budget Plan | | | | ចំណាយជាក់ស្តែងប្រចាំឆ្នាំ Actual Expenditure | | | | ចំណាយបូកយោង Cumulative Expenditure | | | | សមតុល្យថវិកា Ending Balance | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ជំពូក Chapter | គណនី Accounts | អនុគណនី Sub-Account | | | ថវិកាបដិភាគ Counterpart Funds | ឥណទាន Loan | ហិរញ្ញប្បទានឥតសំណង Grants | សរុប Total | ថវិកាបដិភាគ Counterpart Funds | ឥណទាន Loan | ហិរញ្ញប្បទានឥតសំណង Grants | សរុប Total | ថវិកាបដិភាគ Counterpart Funds | ឥណទាន Loan | ហិរញ្ញប្បទានឥតសំណង Grants | សរុប Total | ថវិកាបដិភាគ Counterpart Funds | ឥណទាន Loan | ហិរញ្ញប្បទានឥតសំណង Grants |
| 21 | អចលនកម្មរូបី | | | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | 21xx | | | | | | | | | | | | | | | | | | |
| | | 21xxx | | | | | | | | | | | | | | | | | |
| | | 21xxx | | | | | | | | | | | | | | | | | |
| 60 | ការទិញ | | | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | 60xx | | | | | | | | | | | | | | | | | | |
| | | 60xxx | | | | | | | | | | | | | | | | | |
| | | 60xxx | | | | | | | | | | | | | | | | | |
| 61 | សេវាកម្ម | | | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | 61xx | | | | | | | | | | | | | | | | | | |
| | | 61xxx | | | | | | | | | | | | | | | | | |
| | | 61xxx | | | | | | | | | | | | | | | | | |

| ប្លង់គណនេយ្យ (CoA) | | | បរិយាយ Description | កំណត់សំគាល់ Notes | ផែនការថវិកាប្រចាំឆ្នាំ Annual Budget Plan | | | | ចំណាយជាក់ស្តែងប្រចាំឆ្នាំ Actual Expenditure | | | | ចំណាយបូកយោង Cumulative Expenditure | | | | សមតុល្យថវិកា Ending Balance | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ជំពូក Chapter | គណនី Accounts | អនុគណនី Sub-Account | | | ថវិកាបដិភាគ Counterpart Funds | ឥណទាន Loan | ហិរញ្ញប្បទានឥតសំណង Grants | សរុប Total | ថវិកាបដិភាគ Counterpart Funds | ឥណទាន Loan | ហិរញ្ញប្បទានឥតសំណង Grants | សរុប Total | ថវិកាបដិភាគ Counterpart Funds | ឥណទាន Loan | ហិរញ្ញប្បទានឥតសំណង Grants | សរុប Total | ថវិកាបដិភាគ Counterpart Funds | ឥណទាន Loan | ហិរញ្ញប្បទានឥតសំណង Grants |
| 62 | អត្ថប្រយោជន៍សង្គម | | | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | 62xx | | | | | | | | | | | | | | | | | | |
| | | 62xxx | | | | | | | | | | | | | | | | | |
| | | 62xxx | | | | | | | | | | | | | | | | | |
| 63 | ពន្ធនិងអាករ | | | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | 63xx | | | | | | | | | | | | | | | | | | |
| | | 63xx | | | | | | | | | | | | | | | | | |
| | | 63xx | | | | | | | | | | | | | | | | | |
| 64 | បន្ទុកបុគ្គលិក | | | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | 64xx | | | | | | | | | | | | | | | | | | |
| | | 64xxx | | | | | | | | | | | | | | | | | |
| | | 64xxx | | | | | | | | | | | | | | | | | |
| សរុបរួម (Grand Totals) | | | | | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |

| ហត្ថលេខានិងត្រា<br>រដ្ឋមន្ត្រី | ហត្ថលេខា<br>ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ | ហត្ថលេខា<br>អ្នកធ្វើតារាង |
|---|---|---|

ក្រសួង....................

Ministry of .......................

ឈ្មោះគម្រោង/Project's Name......

លេខគម្រោង/Project No.:xxxxx

ឧបសម្ព័ន្ធ ៦

# របាយការណ៍ចំណូលថវិកាតាមជំពូក គណនី អនុគណនីប្រចាំឆ្នាំរបស់គម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍

## STATEMENT OF RECEIPTS BY CHAPTER ACCOUNTS AND SUB-ACCOUNTS FOR DP FUNDED PROJECTS

## ពីថ្ងៃទី ១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤

From 1st January to 31th December 2024

ឯកតា៖ដុល្លារ

| លរ/ No. | ប្លង់គណនេយ្យ (CoA) | | | បរិយាយ Description | កំណត់សំគាល់ Notes | ផែនការប្រចាំឆ្នាំ (Annual Plan) | | | | ចំណូលជាក់ស្តែង (Current Year Receipts) | | | | ស្ថានភាពអនុវត្ត (Status) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ជំពូក Chapter | គណនី Accounts | អនុគណនី Sub-Account | | | ថវិកាបដិភាគ Counterpart Funds | ឥណទាន Loan | ហិរញ្ញប្បទានឥតសំណង Grants | សរុប Total | ថវិកាបដិភាគ Counterpart Funds | ឥណទាន Loan | ហិរញ្ញប្បទានឥតសំណង Grants | សរុប Total | ថវិកាបដិភាគ Counterpart Funds % | ឥណទាន Loan % | ហិរញ្ញប្បទានឥតសំណង Grants % |
| | | | | | | 1 | 2 | 3 | 4=1+2+3 | 5 | 6 | 7 | 8=5+6+7 | 9=1/5 | 10=2/6 | 11=3/7 |
| ១ | ៧៥ | ៧៥១១ | ៧៥១១១ | ថវិកាបដិភាគ (Counterpart) | | | | | | | | | | | | |
| | ៧៥ | ៧៥១១ | ៧៥១១១ | ការទូទាត់ត្រង់ (Direct Payment) | | | | | | | | | | | | |
| សរុបរួមថវិកាបដិភាគ (Sub-Total Counterpart Funds) | | | | | | | | | | | | | | | | |
| ២ | ៥០ | ៥០០២ | ៥០០២១ | ថវិកាឥណទាន (Loan fund no.) | | | | | | | | | | | | |
| | ៥០ | ៥០០២ | ៥០០២១ | ថវិកាឥណទាន (Loan fund no.) | | | | | | | | | | | | |
| | ៥០ | ៥០០២ | ៥០០២១ | ការទូទាត់ត្រង់ (Direct Payment) | | | | | | | | | | | | |
| សរុបរួមថវិកាឥណទាន (Sub-Total Loan Funds) | | | | | | | | | | | | | | | | |
| ៣ | ៧៥ | ៧៥១៤ | ៧៥១៤២ | ហិរញ្ញប្បទានឥតសំណង (Grant fund no.) | | | | | | | | | | | | |

| លរ/ No. | ប្លង់គណនេយ្យ (CoA) | | | បរិយាយ Description | កំណត់សំគាល់ Notes | ផែនការប្រចាំឆ្នាំ (Annual Plan) | | | | ចំណូលជាក់ស្តែង (Current Year Receipts) | | | | ស្ថានភាពអនុវត្ត (Status) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ជំពូក Chapter | គណនី Accounts | អនុគណនី Sub-Account | | | ថវិកាបដិភាគ Counterpart Funds | ឥណទាន Loan | ហិរញ្ញប្បទានឥតសំណង Grants | សរុប Total | ថវិកាបដិភាគ Counterpart Funds | ឥណទាន Loan | ហិរញ្ញប្បទានឥតសំណង Grants | សរុប Total | ថវិកាបដិភាគ Counterpart Funds % | ឥណទាន Loan % | ហិរញ្ញប្បទានឥតសំណង Grants % |
| | ៧៥ | ៧៥១៤ | ៧៥១៤២ | ហិរញ្ញប្បទានឥតសំណង (Grant fund no.) | | | | | | | | | | | | |
| | ៧៥ | ៧៥១៤ | ៧៥១៤២ | ការទូទាត់ត្រង់ (Direct Payment) | | | | | | | | | | | | |
| សរុបរួមថវិកាជំនួយឥតសំណង (Sub-Total Grants Funds) | | | | | | | | | | | | | | | | |
| សរុបរួម (Grand Total) | | | | | | | | | | | | | | | | |

ហត្ថលេខានិងត្រា
រដ្ឋមន្ត្រី

ហត្ថលេខា
ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ

ហត្ថលេខា
អ្នកធ្វើតារាង

ក្រសួង....................

Ministry of .......................

ឈ្មោះគម្រោង / Name......

លេខគម្រោង/Project No.:xxxxx

ឧបសម្ព័ន្ធ ៧

# របាយការណ៍ស្តីពីស្ថានភាពសាច់ប្រាក់ប្រចាំឆ្នាំរបស់គម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍

## STATEMENT OF ANNUAL PROJECT CASH STATUS FOR DP FUNDED PROJECTS

ពីថ្ងៃទី ១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤

From 1st January to 31th December 2024

ឯកតា៖ដុល្លារ

| ឥណទាន /ហិរញ្ញប្បទានឥតសំណង/ ថវិកាបដិភាគ Loan/Grant/Counterpart Funds | បរិយាយ Descriptions | កំណត់សំគាល់ Notes | សមតុល្យដើមគ្រា Beginning Balance | ចំណូល Receipts | ចំណាយ Expenditure | សមតុល្យចុងគ្រា Ending Balance |
|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4=1+2-3 |
| ថវិកាឥណទាន (Loan fund no.) | សាច់ប្រាក់នៅធនាគារ/ CASH AT BANK | | | | | |
| ថវិកាឥណទាន (Loan fund no.) | សាច់ប្រាក់នៅធនាគារ/ CASH AT BANK | | | | | |
| ហិរញ្ញប្បទានឥតសំណង (Grant fund no.) | សាច់ប្រាក់នៅធនាគារ/ CASH AT BANK | | | | | |
| ហិរញ្ញប្បទានឥតសំណង (Grant fund no.) | សាច់ប្រាក់នៅធនាគារ/ CASH AT BANK | | | | | |
| ថវិកាបដិភាគ (Counterpart funds) | សាច់ប្រាក់នៅធនាគារ/ CASH AT BANK | | | | | |
| សរុបរួម (TOTAL) | | | | | | |

| ហត្ថលេខានិងត្រា | ហត្ថលេខា | ហត្ថលេខា |
|---|---|---|
| រដ្ឋមន្ត្រី | ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ | អ្នកធ្វើតារាង |

រាជធានី ខេត្ត.............

មន្ទីរ............................

ឧបសម្ព័ន្ធ ៨

# របាយការណ៍ចំណូលថវិកាថ្នាក់ជាតិ
## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

ឯកតា៖រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត ជាក់ស្តែង | សមាមាត្រ (%) | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣=២/១ | |
| | | | | | | | |
| | | | សរុបរួម | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខានិងត្រា<br>ប្រធានរតនាគារ<br>រាជធានី ខេត្ត | ហត្ថលេខានិងត្រា<br>ប្រធានមន្ទីរសេដ្ឋកិច្ច<br>និងហិរញ្ញវត្ថុ | ហត្ថលេខានិងត្រា<br>ប្រធានមន្ទីរ | ហត្ថលេខា<br>អ្នកធ្វើតារាង |

រាជធានី ខេត្ត.......................
មន្ទីរ.......................................

ឧបសម្ព័ន្ធ ៩

# របាយការណ៍ចំណាយថវិកាថ្នាក់ជាតិ
# សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

ឯកតា៖រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | ចលនាឥណទាន | | | | | ឥណទានវិចារណកម្ម | ស្ថានភាពឥណទានថ្មី | អនុវត្តជាក់ស្តែង | ឥណទាននៅសល់ | សមាមាត្រ (%) | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | កើន | | | | ថយ | | | | | | |
| | | | | | ចលនាផ្ទៃក្នុង | ឥណទានមិនបានគ្រោងទុក | បំពេញបន្ថែម | សរុប | | | | | | | |
| | | | | ១ | ២ | ៣ | ៤ | ៥=២+៣+៤ | ៦ | ៧ | ៨=១+៥-៦-៧ | ៩ | ១០ = ៨-៩ | ១១ = ៩/៨ | ១២ |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខានិងត្រា<br>ប្រធានរតនាគារ<br>រាជធានី ខេត្ត | ហត្ថលេខានិងត្រា<br>ប្រធានមន្ទីរសេដ្ឋកិច្ច<br>និងហិរញ្ញវត្ថុ | ហត្ថលេខានិងត្រា<br>ប្រធានមន្ទីរ | ហត្ថលេខា<br>អ្នកធ្វើតារាង |

ក្រសួង.......................

គ្រឹះស្ថានសាធារណៈរដ្ឋបាល......

| ឧបសម្ព័ន្ធ ១០ |
|---|

# របាយការណ៍ចំណូលថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

ឯកតា៖រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត ជាក់ស្ដែង | សមាមាត្រ (%) | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣=២/១ | |
| | | | សរុបរួម (I+II+III+IV) | | | | |
| | | | I-ឧបត្ថម្ភធនថវិការដ្ឋ | | | | |
| | | | II-អំណោយនិងអច្ច័យទាន | | | | |
| | | | III-សេវាសាធារណៈឬភាគទាន | | | | |
| | | | IV-កម្រៃ ឬលក់ទ្រព្យសម្បត្តិរដ្ឋ | | | | |
| | | | សរុបរួម | | | | |

ហត្ថលេខា
គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល

ហត្ថលេខា
មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ

ហត្ថលេខានិងត្រា
នាយកគ្រឹះស្ថាន

ហត្ថលេខា
អ្នកធ្វើតារាង

ក្រសួង.......................
គ្រឹះស្ថានសាធារណៈរដ្ឋបាល.............



# របាយការណ៍ចំណាយថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

ឯកតា៖រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | ចលនាឥណទាន | | | | | ស្ថានភាពឥណទានថ្មី | អនុវត្តជាក់ស្តែង | ឥណទាននៅសល់ | សមាមាត្រ (%) | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | កើន | | | | ថយ | | | | | |
| | | | | | ចលនាផ្ទៃក្នុង | ឥណទានមិនបានគ្រោងទុក | បំពេញបន្ថែម | សរុប | | | | | | |
| | | | | ១ | ២ | ៣ | ៤ | ៥=២+៣+៤ | ៦ | ៧=១+៥-៦ | ៨ | ៩ = ៧-៨ | ១០ = ៨/៧ | ១១ |
| សរុបរួម (I+II) | | | | | | | | | | | | | | |
| ១-សរុបចំណាយចរន្ត | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ២-សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |

ហត្ថលេខា
គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល

ហត្ថលេខា
មន្រ្តីត្រួតពិនិត្យហិរញ្ញវត្ថុ

ហត្ថលេខានិងត្រា
នាយកគ្រឹះស្ថាន

ហត្ថលេខា
អ្នកធ្វើតារាង

ក្រសួង ស្ថាប័ន....................

ឧបសម្ព័ន្ធ ១២

របាយការណ៍ស្តីពីស្ថានភាពសាច់ប្រាក់បុរេប្រទានពីរតនាគារជាតិ

ពីថ្ងៃទី ១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤

| | បរិយាយ | តួលេខ ជាប្រាក់រៀល | ផ្សេងៗ |
|---|---|---|---|
| 1 | សមតុល្យសាច់ប្រាក់ដើមគ្រា (បុរេប្រទានមិនទាន់ទូទាត់) | | |
| 2 | សាច់ប្រាក់បុរេប្រទានដែលបានទទួល ក្នុងឆ្នាំ | | |
| 3 | សាច់ប្រាក់បុរេប្រទានដែលបានចំណាយ ក្នុងឆ្នាំ | | |
| 4=1+2-3 | សមតុល្យសាច់ប្រាក់ចុងគ្រា (បុរេប្រទានមិនទាន់ទូទាត់) | | |

ហត្ថលេខានិងត្រា
រដ្ឋមន្ត្រី

ហត្ថលេខា
ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ

ហត្ថលេខា
អ្នកធ្វើតារាង